# ការសំភាសន៍របស់អ្នកមីង ចក់ ចន្ថា

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍មាន ចក់ ចន្ថា

## ការសង្ខេបប្រវត្តិរបស់ អ្នកមីង ចក់ ចន្ថា

អ្នកមីង ចក់ ចន្ថា មានអាយុ48ឆ្នាំនៅក្នុងឆ្នាំ2018 អ្នកមីង ចក់ ចន្ថា មានភេទស្រី អ្នកមីង ចក់ ចន្ថា មានទីលំនៅបច្ចុប្បន្ននៅភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណមីងដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់មីង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹងប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍មីង ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់មីងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ទុកអោយកូនចៅជំនាន់ក្រោយរបស់មីងបានស្គាល់នឹងបានដឹងដែរទេមីង មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ ចា៎!!យល់ព្រម

កៈ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី26ខែ3 ឆ្នាំ2018 ចឹងភូមិនឹងភូមិត្នោតជ្រុំហោសមីង?

ខៈ នៅភូមិត្នោតជ្រុំ

កៈ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

ខៈ នឹងហើយចឹង

កៈ ចឹងសំរាប់មីងឈ្មោះពេញរបស់មីងនឹងមានឈ្មោះអីគេដែរទៅមីង?

ខៈ ខ្ញុំឈ្មោះចក់ ចន្ថា

កៈ ចុះមានឈ្មោះហៅក្រៅទេមីង?

ខៈ ហៅឈ្មោះថានឹង

កៈ ហៅឈ្មោះថាចឹងតែម្តងនឹងហោសមីង
ចុះកាលពីក្មេងមាននរណាហៅឈ្មោះមីងអីផ្សេងទេ?

ខៈ អត់មានទេហៅតែថានឹង

កៈ ចុះមីងអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំមានអាយុកើតនៅឆ្នាំ1970

កៈ ចឹងមីងកើតនៅឆ្នាំ1970ហោសមីង?

ខៈ ចាំ!!នឹងហើយ

កៈ ចឹងមីងអាយុ48ឆ្នាំ?

ខៈ ចាំ!!ខ្ញុំអាយុ48ឆ្នាំ

កៈ ចឹងមីងកើតនៅឆ្នាំ1970 ប៉ុន្តែមីងដឹងថ្ងៃខែទេមីង?

ខៈ អត់ដឹងទេនឹង

កៈ ចឹងអត់ដឹងទេណាមីងណា?

ខៈ ចាំ!!អត់ដឹងទេនឹង

កៈ ចុះមីងឆ្នាំច័ន្ទគតិមីងឆ្នាំអីគេដែរលក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសមីង?

ខៈ ខ្ញុំនៅឆ្នាំរកា

កៈ ចុះមីងកើតនៅណាដែរមីង?

ខៈ ខ្ញុំកើតនៅស្ទឹងមានជ័យ ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ

កៈ នៅរាជធានីភ្នំពេញ?

ខៈ បាទនៅរាជធានីភ្នំពេញ

កៈ អូ៎!!ពីមុននឹងគេហៅភូមិដំណាក់ធំហោសមីង?

ខៈ ចា៎!!នៅនេះនឹង

កៈ ចុះនៅខ័ណ្ឌអីគេដែរមីង?

ខៈ អត់ដឹងខ័ណ្ឌអីគេដែរទេនឹង

កៈ បាទមីងបាទ?

ខៈ នៅភូមិដំណាក់ធំ នៅសង្កាត់ស្ទឹងមានជ័យនឹងហាស

កៈ ចុះសំរាប់មីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខៈ ខ្ញុំមានបងប្អូនចំនួន7នាក់នឹង

កៈ ចឹងមានបងប្អូនចំនួន7នាក់ហោសមីង?

ខៈ ចា៎!!នឹងហើយ

កៈ ប៉ុន្តែដូចជាពួកគាត់នៅរស់ទាំងអស់រឺមួយក៏ស្លាប់ខ្លះដែរមីង?

ខៈ គាត់ស្លាប់អស់3នាក់

កៈ ស្លាប់អស់3នាក់ចឹងបងប្អូនមីង7នាក់នៅសល់

ខៈ នៅសល់តែ4នាក់ទេ

កៈ មានប៉ុន្មានមីង?

ខៈ មានបងប្អូន7នាក់ស្លាប់អស់3នាក់នៅសល់4នាក់នឹង

កៈ ចុះមានប្រុសប៉ុន្មាននាក់ ហើយនឹងស្រីប៉ុន្មាននាក់ដែរមីង?

ខៈ មានប្រុស3នាក់នឹង

កៈ មានស្រី4នាក់ចឹងមីង?

ខៈ ទេមិនមែនប៉ុណ្ណឹងទេមិនមែន7នាក់ទេ
ឥឡូវនឹងនៅសល់4នាក់ត្រូវហើយនឹង7នាក់នឹងហើយ មានស្រី3នាក់នឹងប្រុស4នាក់

កៈ  មានស្រី4នាក់នឹងប្រុស3នាក់ ប៉ុន្តែ?

ខៈ  ទេមានតែស្រី3នាក់ នឹងប្រុស3នាក់នឹង

កៈ  មានស្រី3នាក់នឹងប្រុស3នាក់?

ខៈ  មានស្រី4នាក់មើលស្លាប់ថាត ចិន ធូរ ចាន់ធូ នឹងស្រី ចាន់ថានឹងប្រុស ចិន នឹងប្រុសស្លាប់3នាក់

កៈ  ស្លាប់មានស្រីនឹង

ខៈ  ស្លាប់នឹងប្រុស2នាក់នឹងស្រីម្នាក់

កៈ  ប្រុស2នាក់នឹងស្រីម្នាក់ ចុះនៅសល់សព្វថ្ងៃវិញ?

ខៈ  នៅសព្វថ្ងៃនឹងនៅសល់ស្រី3នាក់នឹងប្រុសម្នាក់

កៈ  អូ៎!!ចឹងមានន័យថាមានស្រី4នាក់នឹងប្រុស3នាក់

ខៈ  នឹងហើយមានប្រុស3នាក់នឹងស្រី4នាក់នឹង

កៈ  ប៉ុន្តែស្លាប់នឹងបងៗៗរឺមួយក៏ប្អូនដែរមីង?

ខៈ  ស្លាប់នឹងប្អូនរបស់ខ្ញុំទេ

កៈ  អូ៎!!ចុះមីងជាកូនទីប៉ុន្មានដែរមីង?

ខៈ  ខ្ញុំជាកូនទី1នឹង

កៈ  មីងជាកូនទី1 អូចឹងអ្នកដែរស្លាប់នឹងសុទ្ធតែជាប្អូនៗៗរបស់មីងទាំងអស់នឹងហោសមីង?

ខៈ  សុទ្ធតែជាប្អូនៗៗទាំងអស់នឹង

កៈ  គាត់ស្លាប់ដោយសារតែមូលហេតុអីគេដែរមីង?

ខៈ  អើរកាលពីនៅអាពតនឹងស្លាប់ស្លាប់ដោយសារតែឈឺរាគហាស

កៈ  បាទមីងបាទ?

ខ៖  នឹងហើយឈឺរាគដែរនឹងហាសប្អូនប្រុសដែរស្លាប់នឹង

ក៖  អ៎ូ!!បាទមីងបាទ?

ខ៖  នឹងកើតនៅឆ្នាំរោង

ក៖  ប៉ុន្តែអ្នកដែរស្លាប់នឹងមានឈ្មោះអីគេដែរមីង?

ខ៖  ឈ្មោះអាចិនពេលដែរស្លាប់នៅអាពតនឹងហាស

ក៖  ប៉ុន្តែចង់និយាយថាប្អូនរបស់មីងដែរបន្ទាប់មីងហាស?

ខ៖  អ៎ូ!!ចង់និយាយថាអ្នកដែរមិនទាន់ស្លាប់នឹងហោស?

ក៖  ទាំងអ្នកស្លាប់នឹងអ្នកដែរមិនទាន់ស្លាប់ហាសពួកគាត់មានឈ្មោះអីគេខ្លះដែរមីង?

ខ៖  ឥឡូវនឹងខ្ញុំនឹងប្រាប់ទីមួយនឹងខ្ញុំឈ្មោះចក់ ចន្ថា

ក៖  បាទមីងបាទ?

ខ៖  ទីពីរនឹងមានឈ្មោះចក់ ចាន់ធី ប្អូនទៅបីនឹងមានឈ្មោះថា ចក់ ចាន់ថាន អ្នកដែរៗៗនៅនឹងទេណាស់

ក៖  បាទមីងបាទ?

ខ៖  ទីបួននឹងមានឈ្មោះ ចក់ ចាន់ថៃន

ក៖  ចឹងមីងដាក់អោយគាត់សិនទៅនឹង?

ខ៖  ខ្ញុំហើយនឹងប្អូនរបស់ខ្ញុំនឹងទីពីរនឹងនៅរស់ទេ ប៉ុន្តែអ្នកដែរនៅក្រោយនៅអាពតនឹងបានស្លាប់មួយ

ក៖  បាទមីងបាទ?

ខ៖  ដល់ពេលដែរបែកអាពតនឹងមកប្អូនពីរនាក់ទៀតស្លាប់នៅបឹងត្របែកនឹង

ក៖  អ៎ូ!!បាទមីងបាទ?

ខ៖  នឹងបានគ្រប់

កៈ ពួកគាត់ស្លាប់ដោយសារតែអីគេដែរមីង?

ខៈ ស្លាប់នៅជំនាន់អាពតនឹងស្លាប់ដោយសារតែជំងឺក្ដៅរាគហាស

កៈ អ៎ូ!!មិនមែនស្លាប់ដោយសារតែអត់ឃ្លានណាហីមីង?

ខៈ អត់ទេពីព្រោះអីនៅតូចនឹងទើបតែបាន8ខែនឹងទេ

កៈ អ៎ូ!!បាទចឹងហោសមីង?

ខៈ អ្នកដែរស្លាប់នឹងទើបតែបាន8ខែនឹង
ដល់ពេលដែរអាពតមកនឹងចាន់ធូនឹងស្លាប់ដែរដោយសារតែថា ជំងឺរាគនឹងហាស

កៈ បាទមីងបាទនឹង?

ខៈ ជំងឺរាគនឹងដែរ

កៈ បាទចឹងបាទមីង?

ខៈ ហើយក៏ស្លាប់ដែរនឹងបន្ទាប់មកទៀតនឹងប្អូនមួយទៀតនឹងកើតកញ្ជ្រិលហាស
វាលាប់កញ្ជ្រិលហាស

កៈ ប៉ុន្តែគាត់នៅណុងពេលណុងប៉ុណ្ណាដែរទៅមីង?

ខៈ បែកអាពតរួចហើយមកនៅនេះហើយនឹងហាស

កៈ អ៎ូ!!បាទមីងបាទ?

ខៈ មកនៅនេះហើយនឹងហាសនៅឆ្នាំ1980ជាងហើយនឹងហាស

កៈ បាទមីងបាទចឹង?

ខៈ វាបានស្លាប់ដោយសារតែលាប់កញ្ជ្រិលដែរនឹងស្លាប់មួយដែរនឹង

កៈ
ចុះមីងអាចប្រាប់ឈ្មោះប្អូនៗរបស់មីងដែរនៅរស់ហាសពួកគាត់មានឈ្មោះអីគេដែរមីង?

ខៈ ប្អូននៅរស់ហើយមនុស្សស្លាប់នឹងយើងនិយាយអស់ហើយណាស់

កៈ បាទមីងបាទ?

ខ៖ ខ្ញុំស្គាល់ទាំងអស់បន្ទាប់ខ្ញុំនៅរស់នឹងឈ្មោះចាន្ថា
បន្ទាប់មកនឹងឈ្មោះចាន់ធីនឹងនៅរស់ដែរ

ក៖ បាទមីងបាទនឹង?

ខ៖ បន្ទាប់មកនឹងចាន់ថាននៅរស់ដែរនឹង ឈ្មោះចាន់ថៃននឹងនៅរស់ដែរចឹងហាស

ក៖ អូ៎!!ចឹងនៅតែ4នាក់នឹងទេហោសមីង?

ខ៖ ចា៎!!នៅប៉ុណ្ណឹង

ក៖ ប៉ុន្តែនៅប្រុស1នាក់នឹងស្រី3នាក់?

ខ៖ ចា៎ៗ!!នឹងហើយ

ក៖
ចុះមីងអាចប្រាប់ថាមីងមានអនុស្សាវរីយ៍អីជាមួយបងប្អូនរបស់មីងដែរទេកាលពីនៅក្មេង?

ខ៖ អូយ ចង់និយាយថា

ក៖ ដូចជាលេងបិទពួន លេងអីចឹងហាស?

ខ៖ កាលនៅក្មេងនឹងមិនដែរបានលេងអីជាមួយប្អូនដែរទេ

ក៖ ម៉េចចឹងហោសមីង?

ខ៖ ពីព្រោះអីនឹងមានតែពរប្អូនទេ និយាយទៅមិនដែរបានលេងអីជាមួយវាហាស

ក៖ ចឹងមីងកើតមកបាន5ឆ្នាំនឹងមីងចូលពលពតបាត់ហើយនឹងមីង?

ខ៖ ចូលពលពតបាត់ហើយនឹងមានអីលេងទៅ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ហើយនៅពេលដែរបែកពលពតនឹងប្អូនរបស់ខ្ញុំឈ្មោះធីនឹងនៅតូច

ក៖ បាទមីងបាទ?

ខ៖ នៅតូចនឹងមើលវាហើយវាយំហើយយើងអាយុ5ឆ្នាំនៅតូចនឹង

កៈ បាទមីងបាទចឹង?

ខៈ យើងទើបតែ5ឆ្នាំនឹងចាំចឹងហើយអត់ដែរថាបានលេងអីជាមួយប្អូនទេ

កៈ និយាយរួមទៅទៅស្រែអីនឹងក៏អត់ដែរបានទៅដែរណាមីង?

ខៈ អត់ដែរទេ

កៈ អូ៎!!បាទមីងបាទ?

ខៈ ទៅស្រែនឹងទៅស្រែរបៀបម៉េចដែរទៅ?

កៈ ចង់និយាយថាពីមុនយើងធ្លាប់ទៅលេង?

ខៈ កាលពីពលពតនឹងធ្លាប់ដែរតើ!!ធ្លាប់ទៅជាមួយប្អូននឹងគេអោយទៅចាំចាបដែរនឹង

កៈ អូ៎!!ចឹងហោសមីងបាទ?

ខៈ នឹងហើយគេអោយធ្លាប់ទៅចាំចាបដែរនឹងហាស

កៈ អូ៎!!ចឹងបាទមីងចឹង?

ខៈ នឹងហើយចឹង

កៈ ចុះប្អូនរបស់មីងនឹងសព្វថ្ងៃគាត់នៅណាដែរទៅមីង?

ខៈ
ប្អូនរបស់ខ្ញុំនឹងសព្វថ្ងៃនឹងផ្ទះនៅមុខហោសដូចថាវាមិនទាន់មានគ្រួសារទេម្នាក់ណុងហោស

កៈ បាទចឹងបាទ?

ខៈ នៅលីវទេទៅធ្វើការងារនៅរោងចក្របាត់ហើយនឹង

កៈ ចុះស្រីមេនមីង?

ខៈ ស្រីនឹង

កៈ ចុះគាត់អាយុប៉ុន្មានដែរមីង?

ខ៖ គាត់អាយុសែជាងនឹងវាកើតនៅឆ្នាំចិតប៉ុន្មានទេនេះដូចជាឆ្នាំ1973ចឹងហើយនេះ

ក៖ ប៉ុន្តែប្អូនរបស់មីងផ្សេងទៀតវិញមីងនៅពីរនាក់ទៀត?

ខ៖ ពីរនាក់ទៀតនឹងម្នាក់ទៀតនឹងប្រុសឆ្នាំរកានឹងវាដើរតែលេងទេ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ មួយទៀតនៅរាល់ថ្ងៃនឹងដើរតែលេងទេ ដើរលេងដើរអីចឹងទៅណាស់

ក៖ បាទមីងបាទនឹង?

ខ៖ នឹងហើយមួយទៀតនឹងស្រីនៅផ្ទះនឹង

ក៖ បាទមីងបាទ?

ខ៖ គេមានប្តីនៅជាមួយប្តីគេចឹងទៅណាស់

ក៖ ចុះបងប្អូនរបស់មីងនឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខ៖ រាល់ថ្ងៃនឹងប្អូនរបស់មីងមួយទៀតនឹងទៅធ្វើការងារនៅរោងចក្រនឹង

ក៖ បាទមីងបាទចឹង?

ខ៖ មានប៉ុណ្ណឹងសំរាប់ចិញ្ចឹមជីវិតដែរនឹងប៉ុណ្ណឹង

ក៖ អូ៎!!នឹងការងាររបស់គាត់ហោសមីង?

ខ៖
ហើយប្អូនស្រីមួយទៀតនឹងចាំប្តីគេអោយមួយថ្ងៃចឹងបានមួយម៉ឺនទៅពីរម៉ឺនអីចឹងហាស

ក៖ អូ៎!!បាទមីងបាទ?

ខ៖ គេអត់មានការងារអីធ្វើទេ

ក៖ ដោយសារតែគេមានគ្រួសារចឹងគេចាំប្តីណាមីង?

ខ៖ ចា៎!!នឹងហើយអត់មានអីទេ

ក៖ បាទចុះសំរាប់ឪពុករបស់មីងនឹងគាត់មានឈ្មោះអីគេដែរទៅមីង?

ខ៖  គាត់មានឈ្មោះចក់ ជិន

ក៖  គាត់មានឈ្មោះចក់ ជិន ចុះគាត់កើតនៅឆ្នាំណាដែរមីងមានចងចាំទេ ដូចជាគាត់អាយុប៉ុន្មានចឹងហាស?

ខ៖  គាត់កាលពីគាត់ស្លាប់នឹងខ្ញុំចាំនៅក្នុងឆ្នាំ1988កាលពីគាត់ស្លាប់ហាស

ក៖  ប៉ុន្មានឆ្នាំហើយមីង?

ខ៖  គាត់ស្លាប់នឹងហាសអាយុ40ឆ្នាំនឹង

ក៖  ចឹងគាត់ស្លាប់អាយុ40ឆ្នាំ?

ខ៖  នឹងគាត់ស្លាប់ពេលនឹងគាត់ឆ្នាំរកាគាត់អាយុ40ឆ្នាំនឹងហាសពេលដែរគាត់ស្លាប់នឹងរហូតមកដល់ ឥឡូវនឹងមិនដឹងថាអាយុប៉ុន្មានទេនឹង

ក៖  គាត់អាយុ70ឆ្នាំ

ខ៖  គាត់អាយុ70ឆ្នាំជាងហើយហោស

ក៖  គាត់អាយុ70ឆ្នាំគត់នឹង

ខ៖  នឹងហើយគាត់ឆ្នាំរកា

ក៖  ដោយសារតែគាត់ស្លាប់នឹងអាយុ40ឆ្នាំហើយគាត់ឥឡូវនឹងអាយុ78ឆ្នាំ

ខ៖  នឹងហើយ

ក៖  ចឹងមានន័យថាអស់30ឆ្នាំនឹង?

ខ៖  នឹងហើយៗៗចឹង

ក៖  ចុះគាត់កើតនៅណាដែរមីងមានដឹងទេឪពុករបស់មីងហាស?

ខ៖  គាត់នឹងគាត់នឹងហាសកើតនៅកំពង់ធំនឹងហាស

ក៖  គាត់នៅកំពង់ធំហោសមីង?

ខ៖  ស្រុកកំណើតរបស់គាត់នៅកំពង់ធំ

កៈ អូ៎!!បាទ ចុះម្ដាយរបស់មីងនឹងគាត់មានឈ្មោះអីគេដែរទៅមីង?

ខៈ ម្ដាយរបស់ខ្ញុំនឹងមានឈ្មោះនេត ទូច

កៈ បាទមីង ចុះគាត់ប្អូនអាយុតាប៉ុន្មានឆ្នាំដែរមីង?

ខៈ គាត់នឹងឆ្នាំកោ ឆ្នាំរកា ឆ្នាំច នឹងឆ្នាំកោប្អូនគ្នាពីរឆ្នាំនឹង

កៈ ចឹងប្អូនពីរឆ្នាំនឹងចឹងមានន័យថាអាយុ68ឆ្នាំណាមីង?

ខៈ ចា៎!!នឹងហើយ

កៈ ចុះគាត់កើតនៅណាដែរមីងមានដឹងដែរទេ?

ខៈ គាត់កើតនៅភូមិដំណាក់ធំនឹង

កៈ អូ៎!!បាទមីងបាទ?

ខៈ នៅសង្កាត់ស្ទឹងមានជ័យនឹងហាស នឹងហើយចឹង

កៈ ចុះប៉ុន្ដែពួកគាត់ស្លាប់ទាំងពីរនាក់រឺក៏យ៉ាងម៉េចដែរមីង?

ខៈ ម៉ែនៅរស់ទេ

កៈ អូ៎!!ម្ដាយរបស់មីងនៅរស់ទេហោស?

ខៈ ចា៎!!នៅរស់ទេ

កៈ ប៉ុន្ដែឪពុករបស់មីងកាលពីគាត់នៅរស់នៅគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង នឹងចិញ្ចឹមក្រុមគ្រួសារហាស?

ខៈ កាលពីគាត់នៅរស់គាត់បែកពីអាពតនឹងមកគាត់រត់រម៉កកង់

កៈ អូ៎!!គាត់ជាអ្នករត់រម៉កហោស?

ខៈ ចា៎!!គាត់រត់រម៉កកង់នឹងហាស

កៈ ចុះកើតអីដែរបានជាគាត់ស្លាប់ហាសមីង?

ខៈ គាត់ធ្វើកប្រាំ

កៈ គេបានយកពូកគាត់ទៅកប្រាំហោស?

ខៈ គាត់ទៅកប្រាំហើយមកវិញគាត់បានចាញ់
ពេលដែរចាញ់ហើយនឹងគ្មានថ្នាំព្យាបាលអីផងនឹង

កៈ អូ៎!!ចឹងមានន័យថាគាត់ស្លាប់ដោយសារតែជំងឺទេហោសមីង?

ខៈ គាត់ស្លាប់ដោយសារតែជំងឺនឹងហើយជំងឺចាញ់នឹង

កៈ ចុះឪពុករបស់មីងនឹងកាត់ស្លូតរឺមួយក៏កាចដែរមីង?

ខៈ គាត់ស្លូតដែរនឹងហាស

កៈ
ចុះម្តាយរបស់មីងនឹងពីមុននឹងកាលពីគាត់បានតានឹងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរមីង
?

ខៈ កាលពីមុនមកខ្ញុំលឺគាត់និយាយថានៅជាមួយម៉ែគាត់នឹងហោស?

កៈ អូ៎!!បាទមីងបាទ?

ខៈ នៅជាមួយម៉ែគាត់នឹងគាត់ធ្វើស្រែធ្វើអីគេដែរនឹងហាស

កៈ ចឹងគាត់ធ្វើស្រែធ្វើចំការនឹងហោស?

ខៈ គាត់អត់មានចំការទេគាត់ធ្វើតែស្រែទេ

កៈ អូ៎!!ចឹងទេហោស?

ខៈ គាត់ឃ្វាលគោឃ្វាលអីចឹងហាសលឺតែគាត់និយាយចឹង

កៈ អូ៎!!បាទមីងបាទ?

ខៈ ពីព្រោះអីនៅស្រុកនេះមានចំការណានៅស្ទឹងមានជ័យនឹង

កៈ ចុះមីង?

ខៈ ហើយគាត់បេះស្លឹកអំពិលអីលក់ហាស

កៈ អូ៎!!យាយគាត់កាចរឺមួយក៏ស្លូតដែរមីង?

ខ៖ យាយនឹងគាត់ស្លូតដែរនឹងហាស ម៉ែរបស់ខ្ញុំនឹងគាត់ថាគាត់កាច

ក៖ គាត់ថាគាត់កាច?

ខ៖ ចា៎!!គាត់ថាគាត់កាចដែរនឹង

ក៖ ប៉ុន្តែបើតាមជាក់ស្តែងដែរមីងឃើញនឹងគាត់ស្លូតដែរទេ?

ខ៖ នឹងហើយគាត់ងឹតភ្នែកពេលខ្ញុំឃើញខ្ញុំនៅក្មេងពេក
ពេលដែរខ្ញុំស្គាល់នឹងគាត់ងឹតភ្នែកហើយនឹង

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ គាត់ងងឹតភ្នែករហូតនឹងហាស

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ខ្ញុំដឹកដៃគាត់នឹងហាស

ក៖ បាទ
ចុះមីងមានចងចាំទេថាពេលដែរមីងរៀបអាពាហ៍ពិពាហ៍ហាសមីងនៅជាមួយឪពុកម្តាយរប
ស់ មីងចឹងហាសមីង?

ខ៖ នឹងហើយ

ក៖ មីងធ្លាប់មានអនុស្សាវរីយ៍អីជាមួយគាត់ដែរទេលក្ខណះដូចជាទៅស្រែ
ញាំុបាយជុំគ្នាដែរមីងគិតថាមីងចងចាំអត់ភ្លេចហាសមីង?

ខ៖
ខ្ញុំមើលដូចជាអនុស្សាវរីយ៍អីទេដូចថាពេលដែរនៅជាគ្នាជាមួយអត់ទាន់មានប្តីងត់ទាន់មាន
អីនឹង ខ្ញុំនៅជាមួយម៉ែឪនឹងខ្ញុំពិបាករហូតនឹង

ក៖ បាទមីងបាទ?

ខ៖ មើលប្អូនផងៗនិយាយទៅ ខ្ញុំហាសមើលប្អូនផង បោកខោអាវផង
បោកកន្តប់ប្អូនផងនឹងពីមុនមកនឹងហាស

ក៖ បាទមីងបាទ?

ខ៖ ទៅរើសអូសដាំបាយ នឹងស្លអីនឹងលើខ្ញុំតែម្តងនឹង

ក៖ អ៎ូ!!ចឹង?

ខ៖
ហើយខ្ញុំដូចថាមានចិញ្ចឹមជ្រូកអីមួយពីរចឹងហាសកាលនឹងនៅតាមមាត់បឹងនៅតាមបឹងត្របែក នោះទេណាស់

ក៖ អ៎ូ!!បាទមីងបាទ?

ខ៖ រួចដើរកាត់ត្រកួនកាត់អោយជ្រូកស៊ី

ក៖ នៅក្នុងបឹងនឹងហីមីង?

ខ៖ នឹងហើយកាត់ត្រកួនការណុងដុះតាមមាត់បឹងចោល

ក៖ អ៎ូ!!បាទមីងបាទ?

ខ៖ នឹងពួកខ្ញុំដើររើសចឹងដើររើសចឹង

ក៖ នឹងជាប្រវត្តិរបស់មីងកាលពីមីងនៅជាមួយឪពុកម្តាយ?

ខ៖ នឹងប្រវត្តិនៅជាមួយម៉ែឪនឹងហើយ

ក៖ ចុះឪពុករបស់មីងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅមីងទេ?

ខ៖
អត់ដែរដឹងទេពេលដែរខ្ញុំធ្លាប់បានឃើញគាត់ជាមួយម៉ែនឹងគាត់ធ្វើជាទាហ៊ានពីជំនាន់ណុង

ក៖ បាទមីងបាទ?

ខ៖ ខ្ញុំដឹងតែប៉ុណ្ណឹង

ក៖ ចុះម្តាយរបស់មីងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់នៅក្មេងទៅមីងដែរទេ?

ខ៖ គាត់ធ្លាប់ប្រាប់ដែរតើថាគាត់នៅពីក្មេងចឹងទៅឃ្វាលគោ
នឹងទៅបេះស្លឹកអំពិលចឹងគាត់ទូលដើរលក់ រហូតដល់ផ្សារដើមគរអីចឹងហាស

ក៖ បាទមីងបាទ?

ខ៖ នឹងហើយៗៗគាត់ដើរដើររហូតចឹងហាស

ក៖ បាទមីងបាទ?

ខ៖ គាត់ទៅកាប់អូសកាប់អី មានចឹងនឹងហាស

ក៖ អូ៎!!ចឹងហោសមីង?

ខ៖ អត់មានប្រវត្តិអីទេណាស់

ក៖ អូ៎!!ចឹងមានន័យថាពួកគាត់មកនៅភ្នំពេញរហូតតែម្តងនឹងហោសមីង?

ខ៖ នឹងគាត់នៅស្រុកនៅនេះនឹងរហូតនឹង

ក៖ ចឹងមានន័យថាគ្រួសាររបស់មីងនឹងយាយតាគឺអ្នកភ្នំពេញនឹងតែម្តង?

ខ៖ ចា៎!!នឹងហើយ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ អត់ទេបើឪពុករបស់ខ្ញុំនឹងគាត់អ្នកនៅកំពង់ធំទេគាត់នៅកំពង់ធំនឹងហាស

ក៖ បាទមីងបាទ ចុះយាយតាខាងម្តាយនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ យាយតាខាងម្តាយ

ក៖ យាយតាខាងម្តាយរបស់មីងហាស?

ខ៖ ខ្ញុំស្គាល់

ក៖ គាត់មានឈ្មោះអីគេដែរមីង?

ខ៖ គាត់ឈ្មោះយាយហ៊ុន ហើយតានឹងមានឈ្មោះតាពេជ្រ

ក៖ ចុះគាត់កើតនៅណាដែរមីងមានដឹងអត់?

ខ៖ គាត់បើយាយនឹងនៅដំណាក់ធំនឹងដែរនឹង

ក៖ អូ៎!!ចឹងទេហោស?

ខ៖ បើតានៅប្រគូព្រែកជ្រៃនេះនឹង

កៈ ប្រគូព្រែកជ្រៃនឹងនៅណាវិញមីង?

ខៈ នេះនៅនេះអាស្រុកសម្ដេចហ៊ុនសែនធ្វើស្ពានឆ្លងនេះនឹងហាស

កៈ អូ៎!!ខ្ញុំស្គាល់ៗហើយនឹង

ខៈ នឹងហើយនៅនឹងនៅជ្រោយវត្តព្រែកទំហៅវត្តព្រែកជ្រៃនឹងស្រុកគាត់នៅនឹងស្រុកតា

កៈ បាទចុះយាយតាខាងឪពុកវិញស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ យាយតាស្គាល់តើលឺថាឈ្មោះតែអត់ដែរស្គាល់គាត់ទេប៉ុន្តែលឺតែឈ្មោះទេណាស់

កៈ បាទមីងបាទ?

ខៈ ឈ្មោះតាចក់ ចំណែកយាយវិញឈ្មោះយាយទុំ

កៈ អូ៎!!ចឹងទេចុះ?

ខៈ នឹងខ្សែខាងឪពុករបស់ខ្ញុំនឹង

កៈ ចុះគាត់កើតនៅណាដែរមីងមានដឹងអត់?

ខៈ អត់ដឹងទេដឹងតែស្រុកគាត់នៅកំពង់ធំនឹងហាស

កៈ អូ៎!!បាទមីងបាទ?

ខៈ នឹងហើយចឹង

កៈ ចឹងមីងមកនៅទីក្រុងភ្នំពេញនឹងយូរនៅមីង?

ខៈ ខ្ញុំពេលដែរបែកអាពតនឹងមកឪពុករបស់ខ្ញុំមកពីកំពង់ធំនឹងគេជំលាសមកហាស

កៈ បាទមីងបាទ?

ខៈ មកចឹងមកនៅភ្នំពេញនឹងតាំងពីឆ្នាំ1979

កៈ រហូតមកដល់ឥឡូវនឹងមែនទេមីង?

ខៈ ចា៎!!នឹងហើយរហូតមកដល់ឥឡូវនឹង

កៈ វាអស់39ឆ្នាំណាមីង?

ខ៖ នឹងហើយ

ក៖ ប៉ុន្តែមីងមានបងប្អូនរឺមួយក៏កូនចៅកូនក្មួយ
រឺជីដូនមួយណាដែររស់នៅក្រៅប្រទេសទេមីង?

ខ៖ អត់មានទេនឹង

ក៖ ចឹងអត់មានទេហោសមីងនៅថៃ វៀតណាមអីក៏អត់មានដែរណាមីង?

ខ៖ អត់ទាំងអស់នឹងហាស

ក៖ អូ៎!!បាទមីងចុះស្វាមីរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខ៖ គាត់មានឈ្មោះឈុន សុខ

ក៖ ប៉ុន្តែមីងមានចងចាំថាមីងបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេ?

ខ៖ ខ្ញុំនៅចាំតែនៅឆ្នាំ1988នឹង

ក៖ ចឹងនៅឆ្នាំ1988ប៉ុន្តែថ្ងៃខែមីងអត់បានចងចាំទេ?

ខ៖ ចា៎!!អត់មានបានចងចាំទេ

ក៖
ចឹងសំរាប់មីងពេលដែរមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយពូនឹងដូចជាមីងចិត្តឯងជាអ្នករៀបចំដោយ ខ្លួនឯងរឺមួយឪបុកម្តាយជាអ្នករៀបចំអោយដែរមីង?

ខ៖ ឪពុកម្តាយគាត់ជាអ្នករៀបចំអោយនឹង

ក៖ ចឹងឪពុកម្តាយណាមីង
ប៉ុន្តែកាលពីពូចូលស្តីដណ្តឹងមីងនឹងពេលណុងមានជាជំនូនជូនមីងដែរទេ?

ខ៖ ពេលណុងនេះទេពេលដែរគាត់មកចូលស្តីដណ្តឹងនឹងនិយាយទៅគាត់កំព្រា

ក៖ អូ៎!!បាទមីង?

ខ៖ គាត់កំព្រារួចទៅអ្នកជិតខាងនឹង

ក៖ គេបានជួយគាត់ចឹងទៅ?

ខ៖ គេបានជួយគាត់ជួយស្តីអោយជាមួយចាស់ៗៗចឹងទៅណាស់

ក៖ អូ៎!!បាទចឹងហោសមីង?

ខ៖ វាមានតែប៉ុណ្ណឹង

ក៖ ចុះមីងចេះអានអក្សរខ្មែរឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណា
ដែរមីងដូចជាមីងធ្លាប់បានរៀនដែរទេ?

ខ៖ ធ្លាប់បានរៀន

ក៖ ចុះមីងរៀនបានថ្នាក់ទីប៉ុន្មានដែរមីង?

ខ៖ រៀនបានត្រឹមតែថ្នាក់ទី4នឹងណាស់

ក៖ អូ៎!!បាទចុះកាលពីមីងរៀននឹងតើមីងរៀននៅណាវិញមីង?

ខ៖ រៀននៅសាលាបឹងត្របែកនេះនឹងបឹងត្របែកខាងជើង

ក៖ សាលាឈ្មោះអីគេដែរមីងសាលាវិទ្យាល័យបឹងត្របែកខាងជើងនឹងហោស?

ខ៖ ចា៎!!នឹងហើយចឹង

ក៖ អូ៎!!បាទមីង
ចុះកាលបីមីងរៀននឹងមីងធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាដែរទេ?

ខ៖ អត់ទេពីព្រោះខ្ញុំបែកនឹងពីព្រោះអីខ្ញុំពេលនឹងអត់ពេលពុកស្លាប់ហោស

ក៖ បាទមីងបាទ?

ខ៖ ពេលពុកស្លាប់ទៅក៏អត់ទៅនឹងហើយអត់មានពេលរៀនទេ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ទៅដើរបេះត្រកួនបេះអីលក់ចឹងទៅ

ក៖ បាទមីងបាទចឹងៗៗ?

ខ៖ ទៅបេះនឹងគេនឹងឯងចឹងទៅណាស់

កៈ ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរទេចឹងមីង?

ខៈ អត់ផងនឹងចេះតែភាសាខ្មែរសុទ្ធនឹង

កៈ ភាសាបារាំងអីក៏មីងអត់ចេះដែរ?

ខៈ អត់ចេះទេ

កៈ អូ៎!!បាទមីងបាទ ចុះមីងគិតថាមីងធ្លាប់ការងារអីគេខ្លះដែរ តាំងពីក្មេងរហូតមកដល់ពេលនេះហាសនៅក្នុងជីវិតរបស់មីងហាស?

ខៈ តាំងពីតូចមកនឹងមែន?

កៈ បាទពីតូចមីងធ្លាប់បានធ្វើអីគេខ្លះដែរ ហើយរហូតមកដល់ពេលឥឡូវនឹងមីងធ្លាប់បានធ្វើអីគេខ្លះចឹង?

ខៈ ពីតូចមកធ្លាប់បានដើរទៅរកត្រី រកក្តាមរកអីនឹងគេនឹងឯងចឹងទៅ ហើយនៅបន្ទាប់មកនឹងបែកអាពត នឹងមកនឹងខ្ញុំរៀងត្រើសបន្តិចចឹងទៅបេះត្រកួនទៅលក់នឹងគេចឹង គេធំៗនឹងទៅនឹងគេនឹងឯងដែរចឹងទៅណាស់

កៈ បាទមីងបាទ?

ខៈ ធ្លាប់នឹងឯងធ្លាប់ចឹងធ្លាប់ដើរបេះត្រកួននឹងធ្លាប់បេះកាលពីនៅប៉ុនៗៗនេះអីនឹងហាស ធ្លាប់នៅបឹងត្របែកអីនឹងបេះកំប្លោកហាសអាដើមកំប្លោកនឹងជ្រៀកវាធ្វើជាខ្សែ

កៈ បាទរហូតមកដល់ឥឡូវនឹងមីងលក់ដូរណាមីង?

ខៈ ចា៎!!នឹងហើយចឹងហើយដាំត្រកួនបន្ទាប់មកនឹង

កៈ អូ៎!!បាទមីងបាទ?

ខៈ បាទដាំត្រកួនហើយបេះត្រកួនលក់នឹង

កៈ ចុះសំរាប់មីងគិតថាមីងធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេមីងស្រែចំការហាសមីងធ្លាប់ធ្វើវាទេ?

ខ៖ ចំការអត់ដែរបានធ្វើទេ

ក៖ ប៉ុន្តែមីងធ្លាប់ធ្វើស្រែ?

ខ៖ ធ្លាប់ស្រែក៏អត់ដែរ

ក៖ ចុះកាលពីជំនាន់ពលពតនឹងគេអោយ?

ខ៖ ជំនាន់អាពតនឹងនៅតូចប៉ុននេះហោសខ្ញុំនៅចាំចាប

ក៖ អូ៎!!គេអោយទៅចាំតែចាបហោសមីង?

ខ៖  នឹងហើយធ្លាប់ទៅចាំចាបនឹងហាស

ក៖ ចុះមីងគិតថាមីងធ្លាប់ទៅបើកអាជីវកម្មលក់ដូរអីទេមីង?

ខ៖ អត់ដែរទេទើបតែមកនឹងទេនឹង

ក៖ ឥឡូវនឹងមីងលក់ឥវ៉ាន់ចាប់ហ្នឹយណាមីង?

ខ៖ ចា៎!!ទើបតែមកនៅនឹងហាស

ក៖ បាទមីង ចុះមីងធ្លាប់ចិញ្ចឹមសត្វមាន់ ចិញ្ចឹមទា ចិញ្ចឹមជ្រូក គោ ក្របីអីទេមីង?

ខ៖ ធ្លាប់ចិញ្ចឹមដែរតើ ធ្លាប់ចិញ្ចឹមមាន់ នឹងចិញ្ចឹមជ្រូកនឹងហាស

ក៖ ប៉ុន្តែមីងចិញ្ចឹមជាលក្ខណះច្រើនរឺមួយក៏ចិញ្ចឹមតិចដែរ?

ខ៖ ចិញ្ចឹមតិចដែរនឹង

ក៖ ចឹងចិញ្ចឹមលក្ខណះជាគ្រួសារណាមីង?

ខ៖ ចា៎!!ចិញ្ចឹមមួយខ្ញុំនិយាយទៅចិញ្ចឹមចាប់ពីពីរឡើងទៅនឹងដឹងតែចិញ្ចឹមអត់រស់ហើយនឹងបើខ្ញុំចិញ្ចឹមមួយៗនឹងអានឹងឆាប់រស់នឹង

ក៖ អូ៎!!បាទមីងបាទ?

ខ៖ នឹងហើយវាចឹង

ក៖ ចុះមីងគិតថាជីវិតរបស់មីងនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរទៅមីង?

ខ៖ មានការផ្លាស់ប្តូរដែរនឹងដូចថាខ្ញុំនៅជាមួយម៉ែឪនឹងពិបាកវេទនាណាស់ ហើយពេលនៅជាមួយប្តីនឹង ក៏ពិបាកដែរប៉ុន្តែគ្រាន់តែថាខ្ញុំខំតស៊ូហាស

ក៖ បាទមីងបាទត្រូវនឹង?

ខ៖ ខ្ញុំខំតស៊ូខ្លួនឯងហាសហើយពេលខ្ញុំមានកូននឹងខ្ញុំថាតឡូវនឹងម៉ែថាកូនឯងនឹងខំរៀនណាស់

ក៖ បាទមីងបាទនឹង?

ខ៖ អោយបានធ្វើការងារអីចឹងទៅណាស់

ក៖ បាទចឹងមីងបាទ?

ខ៖ កុំអោយដូចម៉ាក់ចឹងហាស ហើយប៉ានឹងក៏អត់ចេះដែរដោយសារតែកំព្រីកំព្រាហើយអត់មានម៉ែឪ សំរាប់ផ្គត់ផ្គង់អីចឹងហាសណាស់

ក៖ បាទមីងបាទចឹង?

ខ៖ ហើយខ្ញុំតាំងចិត្តថាពេលខ្ញុំមានកូននឹងខ្ញុំមិនអោយកូនខ្វះខាតដូចអ្វី ដែរខ្ញុំពេលនៅជាមួយម៉ែចឹងហាសណាស់

ក៖ បាទមីងត្រូវហើយមីងនឹង?

ខ៖ នឹងហើយនៅជាមួយម៉ែឪនឹងម៉ែឪគាត់ពិបាកចឹងហាសពេលដែរមានកូននឹង

ក៖ យើងចេះតែខំប្រឹងទៅណាមីង?

ខ៖ កុំអោយកូនពិបាកទៀតនឹងត្រូវខំប្រឹងដោយខ្លួនឯងតែម្តងនឹង

ក៖ បាទមីងបាទ ចុះមីងគិតថាមីងចូលចិត្តម្ហូបអីគេដែរមីងចូលចិត្តពិសារដែរមីង?

ខ៖ ចូលចិត្តជាគេនឹងសំលម្ជូរ

ក៖ អូ!!ចូលចិត្តសំលម្ជូរហោសមីង?

ខ៖ ចា៎!!នឹងហើយ

ក៖ ចុះមីងចេះច្រៀងដែរទេ?

ខ៖ ខ្ញុំចេះតែច្រៀងលេងតិចៗៗនឹងហាស

ក៖ អូ៎!!ភាគច្រើនបទចំរៀងអីដែរមីងចូលចិត្តច្រៀងដែរមីង?

ខ៖ ខ្ញុំមែនចូលចិត្តបទកំសត់ៗៗនឹងហាស

ក៖ បាទមីងបាទ?

ខ៖ នឹងហើយនឹង

ក៖ តែមីងចូលចិត្តស្តាប់បទចំរៀងដែរនឹង?

ខ៖ ចា៎!!ចូលចិត្តនឹង

ក៖ លក្ខណះបទសម័យរឺមួយបទបុរាណដែរមីង?

ខ៖ បទបុរាណនឹងហាស

ក៖ អូ៎!!បាទមីងចុះល្បែងប្រជាប្រិយ៍អីដែរមីងចូលចិត្តលេងតាំងពីក្មេងហាសមីង ដូចជាចោលឈូង លាក់កន្សែង បោះអង្គុញ?

ខ៖ ចា៎!!អូនៅពីក្មេងនឹងពួកខ្ញុំមិនសូវបានដើរលេងដែរទេ

ក៖ អូ៎!!បាទមីងបាទ?

ខ៖ នឹងហើយខ្ញុំនៅតូចៗៗនឹងនិយាយទៅខ្ញុំការអាយុ18ឆ្នាំអីដែរនឹងហាស ហើយពេលណុងមិនដែរបានដើរលេងអីទេនឹង

ក៖ បាទមីងបាទ?

ខ៖ ថាទៅតែរកស៊ីពេលនោះបេះត្រកួនខ្ញុំហាសរៀងធំតិចទៅបេះត្រកួន ដល់ពេលដែរនៅតូចៗៗនឹងទៅ ឈូតកំប្លោកអីជាមួយគេចឹងទៅណាស់

ក៖ បាទមីងបាទ?

ខ៖ នឹងហើយពេលដែរធំឡើងនឹងខ្ញុំបេះត្រកួនលក់នឹង

កៈ អូ៎!!បាទចុះមីងគិតថាមីង?

ខៈ ខ្ញុំមិនសូវបានដើរលេងនឹងគេទេ

កៈ ចុះមីងគិតថាមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់មីងនឹង
គាត់ចេះលេងឧបករណ៍ភ្លេងដែរទេមីង ភ្លេងខ្មែរ ភ្លេងសៀម
រឺមួយក៏ភ្លេងពិនពាតអីចឹងហាសមីង?

ខៈ អត់មានទេ

កៈ ចឹងអត់មានទេណាមីង?

ខៈ ចា៎!!នឹងហើយអត់មានទេ

កៈ ចុះផ្ទះរបស់មីងមានលក្ខណះបែបណាតាំងពីក្មេងពីក្មេងរហូតមកដល់ពេលនេះហាស

ខៈ ផ្ទះនឹងយ៉ាងម៉េចដែរអូន?

កៈ ផ្ទះស្នាក់នៅនឹងហាស ដូចថាផ្ទះថ្ម រឺមួយក៏ផ្ទះឈើចឹងហាស?

ខៈ អូ៎!!អត់ទេពេលខ្ញុំពេលដែរបែកមកនឹងកាលពីខ្ញុំនៅបឹងត្របែកនឹងផ្ទះឈើ

កៈ អូ៎!!ផ្ទះឈើហោសមីង?

ខៈ មានតែ14ម៉ែត្រ3តឹកទេ ហើយក៏លក់មកពីនឹងមកនៅបឹងទំពុននឹងបានធ្វើផ្ទះហាស

កៈ បាទមីងបាទ?

ខៈ
បានបានធ្វើផ្ទះហាសធ្វើផ្ទះឈើដែរនឹងធ្វើផ្ទះឈើបន្ទាប់មកពេលនោះបន្ទះឬស្សីរនាបទេ
ណាស់

កៈ បាទមីងបាទនឹង?

ខៈ បន្ទាប់មកលក់បានលុយមកបានមកធ្វើនៅនេះ បានមកទិញនៅបឹងទំពុននេះហាស

កៈ បាទមីងបាទនឹង?

ខៈ បន្ទាប់មកនឹងរដ្ឋគេដូរដីអោយនឹងនៅកន្លែងនេះ

ក៖ បាទមីងបាទ?

ខ៖ ចាំ!!ផ្ទះរបស់ខ្ញុំមុនដំបូងនឹងនៅលើថ្មល់នឹងហាស

ក៖ បាទចឹងអូបាទមីង?

ខ៖ ចាំ!!នឹងហើយចឹងឯង

ក៖ ចុះដូចជាផ្ទះនឹងនរណាគេជាអ្នកសាងសងវាដែរមីង?

ខ៖ ផ្ទះមួយណាដែរ?

ក៖ ផ្ទះមីងនៅបឹងត្របែកហាស?

ខ៖ នឹងឪពុករបស់ខ្ញុំនឹង

ក៖ អូ៎!!ប៉ុន្តែគាត់ចេះធ្វើផ្ទះទេមីង?

ខ៖ គាត់អត់ចេះធ្វើផងនឹង

ក៖ គាត់ជួលគេធ្វើដែរណមីង?

ខ៖ ចាំ!!គាត់ជួលគេធ្វើអោយដែរនឹងហាស

ក៖ អូ៎!!បាទមីងចុះមីងគិតថាជំនាញអីគេដែរមីងចេះស្ទាត់ជំនាញដែរមីង?

ខ៖ ខ្ញុំជំនាញហោសខ្ញុំជំនាញដូចថាបើជំនាញខាងរឿងលក់ដូរនឹងក៏វាម៉្យាងដែរ ពីព្រោះអីខ្ញុំគ្មានអីក្រៅពីអានឹងដែរនឹងមានតែលក់ដូរនឹងហាស

ក៖
បាទមីងចុះគិតថាឪពុកម្ដាយរបស់មីងនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅមីងដែរទេ?

ខ៖ អូយម៉ែឪរបស់ខ្ញុំមិនដែរបានបង្រៀនទេនឹង

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ចាំ!!នឹងហើយអត់ទេ

កៈ ចុះមីងអាចប្រាប់ពីពេលដែរលំបាកនៅក្នុងជីវិតរបស់មីងដែរបានទេ ថាមីងនៅជំនាន់ពលពត នឹងមុនជំនាន់ពលពតនឹងមីងធ្លាប់ជួបទុកលំបាកអីគេខ្លះដែរចឹងហាស?

ខៈ ខ្ញុំចាំដែរនឹង

កៈ មីងអាចនិយាយបានតាមអ្វីដែរមីងបានចាំបានទេ?

ខៈ ខ្ញុំនិយាយបានដែរនឹងចាំមើលហាសខ្ញុំធ្លាប់ជួបលំបាកពេលនៅជំនាន់ពលពតនឹងខ្ញុំនៅតូចដែរនឹង ហាសខ្ញុំដើរទៅចាំចាបចាំអីនឹងគេ

កៈ បាទមីងបាទ?

ខៈ ហើយនឹងមើលប្អូនទៀតប្អូនរបស់ខ្ញុំនឹងនៅផ្ទះជាមួយខ្ញុំនឹងអត់មានខោអាវស្លៀកទេ

កៈ បាទមីងបាទចឹង?

ខៈ ខ្ញុំអីនឹងស្លៀកតែខោលីអូមួយទេណាស់

កៈ បាទមីងបាទ?

ខៈ ហើយប្អូនរបស់ខ្ញុំនឹងវានៅដេកចងអង្រឹងនឹងឡើងស្គមហើយអត់មានភួយដណ្តប់អីទេ

កៈ បាទមីងបាទ?
ខៈ នឹងហើយទុកលំបាកដល់ពេល

កៈ ប៉ុន្តែមួយនឹងលក្ខណៈនៅក្នុងកងកុមាររឺមួយក៏នៅផ្ទះដែរមីង?

ខៈ ខ្ញុំនៅផ្ទះទេម៉ែទៅធ្វើការងារបាត់ហើយនឹង

កៈ អូ៎!!គេមិនអោយមីងទៅកងកុមារទេហោសមីង?

ខៈ អត់ទេខ្ញុំនៅតូចនឹងហើយ

កៈ អូ៎!!បាទមីង ចុះកងកុមារភាគច្រើននឹងចាប់ពីអាយុប៉ុន្មានដែរមីង?

ខៈ ខ្ញុំអត់ដឹងទេខ្ញុំនៅតូចហាស

កៈ បាទមីងបាទនឹង?

ខៈ ចឹងខ្ញុំអត់ដឹងទេនឹង

កៈ ចឹងរហូតទាល់តែមីងមានគ្រួសារនឹងមីងគិតថាមីងមានការលំបាកអីគេដែរទៅមីង?

ខៈ នឹងហើយរហូតនឹងដល់ពេលដែរខ្ញុំនៅជាមួយឪពុករបស់ខ្ញុំនឹង
ភាគច្រើនពិបាកដូចថាឪអត់នៅចឹង
ខ្ញុំខំតស៊ូហើយម៉ែនឹងអត់មានការងារធ្វើអីទេម៉ែនៅតែផ្ទះហោស

កៈ បាទមីងបាទចឹង?

ខៈ
ហើយដល់ពេលចឹងពួកខ្ញុំនឹងទៅបេះកំប្លោកបេះត្រកួនអីនឹងដើម្បីចិញ្ចឹមជីវិតចឹងហាស

កៈ បាទមីងបាទ?

ខៈ នឹងហើយចឹង ហើយដល់ពេលដែរខ្ញុំបានប្តីបានអីនេះនឹងតស៊ូជាមួយគ្នា
ខ្ញុំបេះត្រកួនចឹងគាត់រត់ស៊ីខ្លូនឹងហាស

កៈ ចេះតែខំប្រឹងទៅណាមីង?

ខៈ ខំប្រឹងនឹងហាសទាល់រាល់ថ្ងៃនឹងហាស
សូម្បីតែឥឡូវនឹងក៏ប្តីអត់មានការងារអីគេដែរមកលក់ជាមួយខ្ញុំនឹងហាស

កៈ អូ៎!!បាទមីងបាទ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះមីងគិតថាមីងឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរទៅមីង
ដូចជាពុះពារឧបសគ្គមួយនឹងដោយរបៀបណាដែរចឹងហាស?

ខៈ ឆ្លងកាត់នឹងចេះតែតៗៗមកតែម្តងនឹងហាស

កៈ អូ៎!!ចឹងណាមីងណា?

ខៈ មិនដឹងថាយ៉ាងម៉េចទេពីព្រោះខំតស៊ូដោយខ្លួនឯងនឹងហាស

កៈ បាទមីងបាទនឹង?

ខៈ ខំប្រឹងតែម្ដងនឹងហាស

កៈ បាទមីងបាទត្រូវ?

ខៈ ខំខ្លួចត្រលប់ទៅក្រោយវិញនឹង

កៈ បាទមីងត្រូវបាទមីង?

ខៈ ខំប្រឹងតស៊ូតែម្ដងនឹងហាស

កៈ ចុះពេលណាដែរមីងគិតថាជាពេលដែរសប្បាយនៅក្នុងជីវិតរបស់មីងដែរទៅ?

ខៈ ខ្ញុំឥឡូវនឹងដូចថាពេលនេះខ្ញុំសប្បាយហើយនៅក្នុងជីវិតនឹងហាស

កៈ អូ៎!!ដោយសារតែមីងអស់អីត្រូវបារម្ភណ៍ទៀតហើយណាមីង?

ខៈ
ចាំ!!ដូចថាយើងចង់និយាយថាដូចថាឥឡូវនឹងវាមិនមានវាមិនអីទេគ្រាន់តែថាវាផុតពីមុននឹងវា ពិបាកខ្លាំងហោស

កៈ បាទមីងបាទត្រូវហើយនឹងហាស?

ខៈ ដូចថាឥឡូវនឹងយលងអត់មានអីទីពឹងក្រៅពីការរកស៊ីបន្តិចបន្តួចទេនឹងទេ

កៈ បាទមីងបាទនឹង?

ខៈ ចុះយើងអត់មានដីស្រែ នឹងអត់មានដីអីនឹងគេហាស

កៈ បាទមីងបាទត្រូវហើយនឹង?

ខៈ ចាំ!!មានតែមួយកេនឹងប៉ុន្តែគ្រាន់តែថាយើងអត់ជួលផ្ទះគេនៅនឹងហាស

កៈ
អូ៎!!ស្រួលប៉ុន្តែមីងគិតថាពេលដែរមីងការរឺមួយកូនមីងការនឹងពេលណុងមីងសប្បាយទេ?

ខៈ ពេលណុងពេលដែរកូនការនឹងវា

កៈ វាសប្បាយម៉្យាងណាមីង?

ខ៖ នឹងហើយៗៗចឹង

ក៖ សប្បាយមួយឆាវអីចឹងហោសមីង?

ខ៖ ចឹងខ្ញុំមិនងថាខ្ញុំសប្បាយទេពេលការនឹងខ្ញុំពិបាកចិត្តដែរនឹង

ក៖ វាហាត់ដែរហោសមីង?

ខ៖ មិនថាហាត់មិនថានឿយទេពិបាកចិត្តដូចថាកូននឹងយើងមិនសូវជាពេញចិត្តអីចឹង

ក៖ អូ៎!!បាទមីងបាទ?

ខ៖ ខ្លាចកូននឹងវាពិបាកនឹងខ្ញុំគិតប៉ុណ្ណឹងទេនឹងខ្ញុំនិយាយប៉ុណ្ណឹងបានហើយណាស់

ក៖ បាទមីងបាទចឹងប្រហែលជាខ្ញុំមានពីរសំនួរទៀតទេមីង?

ខ៖ ចា៎!!និយាយមកចឹង

ក៖ ចឹងចុះកាលពីក្មេងនឹងមីងធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹង
មីងធ្លាប់គិតថាចង់ធ្វើអីទេកាលពីមីងនៅរៀនហាស?

ខ៖ ចា៎ៗៗ!!

ក៖ មីងគិតថាមីងចង់ធ្វើជាគ្រូពេទ្យវីមួយក៏គ្រូបង្រៀនអីចឹងហាសមីងធ្លាប់គិតដែរទេ?

ខ៖ អូ៎!!កាលពីនៅរៀននឹងនៅតូចដែរចឹងមិនដឹងថាស្រម៉ៃចង់ធ្វើអីទេ

ក៖ អូ៎!!ចឹងមីងអត់ដែរគិតទេណាមីង?

ខ៖ នឹងហើយអត់ដែរគិតទេនឹងមិនដែរគិតតែម្តងនឹងអត់ដែរបានគិតទេ

ក៖ បាទមីងបាទចឹងជាចុងក្រោយនឹងខ្ញុំមានសំនួរចុងក្រោយខង់សួរមីងថា
តើបើសិនជាចង់អោយមីងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗនឹងមីងចង់ផ្តែផ្តាំអីទៅពួកគាត់
ដែរមីង?

ខ៖ ចា៎!!ខ្ញុំសូមផ្តែផ្តាំថាអោយកូនរបស់ខ្ញុំនឹងខិតខំរៀនសូត្រ
និយាយទៅអោយបានជ្រៅជ្រះទៅនឹង ហើយនឹងអោយបានការងារល្អៗៗធ្វើនឹងគេ

ក៖ បាទមីងបាទនឹង?

ខ៖ កុំអោយដូចម៉ាក់នឹងប៉ាទៀតនឹងហាស

ក៖ បាទមីងបាទ?

ខ៖ នឹងហើយចឹង

ក៖ មីងមានអីដែរមីងចង់ផ្ដែផ្ដាំទៀតរឺមួយក៏ចង់អោយពយកគាត់ជៀសវៀងហាស?

ខ៖ ចា៎!!នឹងហើយផ្ដែផ្ដាំនឹងជៀសវៀង ជៀសវៀងការដើរលេង
ដើរលេងរឺមួយក៏គ្រឿងញៀនអីនឹង

ក៖ បាទត្រូវហើយមីង?

ខ៖ ចា៎!!ផ្ដែផ្ដាំកុំអោយកូននឹងកុំអោយកូននឹងប៉ះពាល់រឿងមួយនឹងសោះ

ក៖ បាទមីងដោយសារតែមួយនឹងវាមិនល្អសំរាប់នៅក្នុងសង្គមនមីង?

ខ៖
ចា៎!!នឹងហើយពីព្រោះអីនឹងសង្គមវាស្អប់ខ្ពើមនឹងយើងកុំប្រព្រឹត្តអោយសោះនឹងហើយចា

ក៖ បាទមីងបាទចុះមានអីដែរមីងចង់ផ្ដែផ្ដាំផ្សេងទៀតទេមីង?

ខ៖ អើរមិនដឹងមានអីទៀតទេនឹង

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណាច្រើនមីងដែរបានអោយខ្ញុំពិភាក្សាជាមួយនឹង
ខ្ញុំដែរទាក់ទងពីប្រវត្តិរបស់មីងបាទអរគុណាច្រើនមីង៕៕៕